# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

**កម្មវិធីរបស់ The Asian International Justice Initiative**

**ឆ្នាំទី១ លេខ ៧** **សប្តាហ៍ទី ៧ (៨ ‐ ១០ មិថុនា ឆ្នាំ២០០៩)**

## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



*រូបភាព: ឌុចក្នុងបន្ទប់សវនាការ*

## ១. សេចក្តីសង្ខេប

*"ដីរងាប់ទោះយកចង្កេមកបាំងក៏មិនជិតដែរ"*[១]

នាសប្តាហ៍នេះ អង្គជំនុំជម្រះ និងភាគីនៅតែបន្តការសួរដេញដោល **ឌុច** ពាក់ព័ន្ធអង្គហេតុ *"ការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១"* និង *"ជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាម"* ។ ចំពោះអង្គហេតុទីមួយមិនមានព័ត៌មានថ្មីច្រើនទេ គឺត្រឹមតែបង្ហាញពីឆន្ទៈ និងគោលការណ៍ឯករាជ្យក្នុងការអនុវត្តន៍មាគ៌ាបក្សរបស់ជនជាប់ចោទនៅមន្ទីរ ស-២១ ។

---

[1] **ឌុច** បានពន្យល់កាលពីថ្ងៃអង្គារ ទី០៩ ខែមិថុនា ឆ្នាំ២០០៩ ទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ ពីការអះអាងរបស់ខ្លួនដែលថា ធ្លាប់បានដោះលែងអ្នកទោស ៣នាក់នោះ គឺមិនពិត ព្រោះខ្លួនគ្មានសិទ្ធិដោះលែងអ្នកទោសដោយគ្មានបញ្ជាពីថ្នាក់លើទេ ។ **ឌុច** រៀបរាប់ថា មិនបានកុហករឿងនេះទេ ព្រោះគាត់បានសារភាពចំពោះឧក្រិដ្ឋកម្មជាច្រើន ដែលបានប្រព្រឹត្តនៅមន្ទីរ ស-២១ ។

ជនជាប់ចោទនៅតែបន្តរក្សាជំហរខ្លួនថា រាល់គំនិតដែលគាត់បានបង្កើត គឺធានាឱ្យមានប្រសិទ្ធិភាពក្នុងប្រតិបត្តិការនៅមន្ទីរ ស-២១ ដើម្បីរក្សាសុវត្ថិភាពខ្លួនចៀសពីគ្រោះថ្នាក់ ។

ជាថ្មីម្តងទៀត ជនជាប់ចោទបានបង្ហាញពីវិប្បដិសារីរបស់ខ្លួនចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តនៅមន្ទីរ ស-២១ ហើយថា *"គាត់មិនបន្ទោសអ្នកក្រោមបង្គាប់ចំពោះការធ្វើទារុណកម្ម និងការសម្លាប់មនុស្សនៅមន្ទីរស-២១ ឡើយ"* ប៉ុន្តែការរៀបរាប់នេះ ហាក់ដូចជាបង្ហាញថា ជាកំហុសរបស់ថ្នាក់លើគាត់ទៅវិញ ដោយ **ឌុច** អះអាងថា រាល់ការអនុវត្តភារកិច្ចរបស់ខ្លួន គឺធ្វើតាមបញ្ជារបស់ថ្នាក់លើ និងមាគ៌ាបក្ស ។

## ២. បញ្ហាច្បាប់ និង នីតិវិធី

### ក. សេចក្តីសង្ខេបសក្ខីកម្មរបស់ជនជាប់ចោទ

ដូចបានកត់សម្គាល់នៅរបាយការណ៍សប្តាហ៍មុន អង្គជំនុំជម្រះបានសម្រេចពិចារណាលើភស្តុតាងពី *"ប្រធានបទមួយទៅប្រធានបទមួយ"* ហើយកិច្ចនីតិវិធីនាសប្តាហ៍នេះនៅតែបន្តការសួរដេញដោលជនជាប់ចោទ អំពីអង្គហេតុទាក់ទងនឹងការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១ និង ជម្លោះប្រដាប់អាវុធដដែល ។ សំណួររបស់សហព្រះរាជអាជ្ញាបានផ្តោតសំខាន់លើឆន្ទៈ**ឌុច** និងការចូលរួមដោយឯករាជ្យ ជាពិសេស អំពីវិធីសាស្ត្រអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១ ។ ចំណែកមេធាវីដើមបណ្តឹងក្រុម១ លើកសក្ខីកម្មរបស់លោកបណ្ឌិត **Craig Etchesson** សួរទៅជនជាប់ចោទដោយផ្ទាល់ (ដែលជនជាប់ចោទហាក់ដូចជាមានអារម្មណ៍មិនប្រក្រតី) ។ ចំពោះមេធាវីការពារក្តីវិញក៏ផ្តោតសំខាន់ទៅលើសក្ខីកម្មរបស់សាក្សីជំនាញរូបនេះដែរ ។ ខាងក្រោមនេះ ជាសេចក្តីសង្ខេបរបស់ជនជាប់ចោទ :

***ការបណ្តុះបណ្តាលនៅមន្ទីរ ស-២១ :*** **ឌុច** បញ្ជាក់ថា ខ្លួនបានសាងសង់សាលារៀនមួយនៅក្បែរផ្ទះ គឺទុកសម្រាប់បណ្តុះបណ្តាលអ្នកសួរចម្លើយនៅមន្ទីរ ស-២១ ។ ការធ្វើបែបនេះ គឺមានភាពងាយស្រួលក្នុងការទំនាក់ទំនងជាមួយថ្នាក់លើ (តាមរយៈទូរសព្ទ័នៅផ្ទះគាត់) ។ មជ្ឈមណ្ឌលនេះក៏ប្រើសម្រាប់កិច្ចប្រជុំប្រចាំឆ្នាំផងដែរ ។ **ឌុច** បានបញ្ជាក់ថា គាត់ជាមនុស្សតែម្នាក់គត់ទទួលបន្ទុកការបណ្តុះបណ្តាលបុគ្គលិក ហើយមិនដែលបង្រៀនអង្គភាពផ្សេងឡើយ ។

***វិធីសាស្ត្របង្រៀន :*** ជនជាប់ចោទពន្យល់ថា នៅពេលបណ្តុះបណ្តាលអ្នកសួរចម្លើយ គាត់បានប្រើវិធីសាស្ត្រឈ្មោះថា *"វាយរហ័សឈ្នះរហ័ស"* មានន័យថា បង្រៀនទ្រឹស្តីពេលព្រឹក ហើយអនុវត្តពេលថ្ងៃ ។ គាត់ថែមទាំងកំណត់ថា *"ការប្រតិបត្តិទ្រឹស្តីវិលជុំ"* គឺជាការទទួលបានចំណេះដឹងជាបន្តបន្ទាប់ និងពង្រឹងអ្វីដែលបានបង្រៀនហើយ ។

***ការអនុវត្តន៍នៃគណៈកម្មការស្វ័យតិះទៀននៅមន្ទីរ ស-២១ :*** **ឌុច** បានអះអាងថា គាត់មិនបានអនុវត្តជាប្រចាំនូវកិច្ចប្រជុំស្វ័យតិះទៀនជាមួយសមាជិកគណៈកម្មការមន្ទីរ ស-២១ ទេ បើទោះជាមានចែងក្នុងលក្ខនិកៈបក្សក៏ដោយ ។ គណៈកម្មការនេះមានសមាជិក ៣រូប គឺ **ឌុច ហូ** និង **ហ៊ុយ** ។ ជនជាប់ចោទបញ្ជាក់ថា សមាជិកមានការទុកចិត្តគ្នាទៅវិញទៅមក ពួកគេគ្រាន់តែផ្តល់

យោបល់ប៉ុណ្ណោះនៅពេលមានកំហុសកើតឡើងម្តងៗ ។ បញ្ហានេះហាក់ដូចជាគាំទ្រសំដីសហព្រះរាជអាជ្ញាដែលថា **ឌុច** អាចចៀសវាងពីការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ។

***គោលនយោបាយកំទេចអ្នកទោសកុមារ :*** នៅពេលឆ្លើយតបសំណួរសហព្រះរាជអាជ្ញាជាតិ លើគោលនយោបាយអនុវត្តចំពោះអ្នកទោសកុមារនៅមន្ទីរ ស-២១ ជនជាប់ចោទបានលើកឡើងថា ក្មេងទាំងនោះត្រូវបានកំទេច ប៉ុន្តែគាត់មិនបានដឹងពីវិធីដែលកូនចៅធ្វើឡើយ ។ **ឌុច** រៀបរាប់ថា ខ្លួនធ្លាប់ប៉ុនប៉ងចញ្ចឹមកូនអ្នកទោស ប៉ុន្តែក្មេងទាំងនោះមិនរស់រៀនមានជីវិតទេ ដោយសារតែកង្វះការថ្នាក់ថ្នម ហើយនៅពេលរឿងនេះដឹងដល់ **សុន សេន** គាត់និយាយថា *"នេះជាមេរៀនមួយសម្រាប់អ្នក... ចញ្ចឹមក្មេង គឺលំបាកអញ្ចឹង ហើយពួកគេអាចនឹងសងសឹកវិញ"* ។

***ឌុចឆ្លើយតបនឹងសក្ខីកម្មលោកបណ្ឌិត Craig Etcheson :*** ជនជាប់ចោទហាក់ដូចជារំជួលចិត្ត នៅពេលដេញដោលជាមួយនឹងសក្ខីកម្មលោកបណ្ឌិត **Etcheson** ដោយមេធាវីដើមបណ្តឹងអន្តរជាតិក្រុម១ ទាក់ទងនឹងការធៀបមន្ទីរ ស-២១ និងមន្ទីរសន្តិសុខដទៃទៀត ដែលថាមន្ទីរ ស-២១ គឺជាមន្ទីរធំតែមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (សូមមើលរបាយការណ៍របស់អ្នកសង្កេតការណ៍តុលាការសប្តាហ៍ទី៥ និងទី៦) ។ **ឌុច** បដិសេធនឹងរបាយការណ៍លោកបណ្ឌិត **Etcheson** ដែលថា បច្ចេកទេសធ្វើទារុណកម្មនៅមន្ទីរ ស-២១ គឺធ្ងន់ធ្ងរជាងមន្ទីរសន្តិសុខដទៃ ទាំងមធ្យោបាយ និងបច្ចេកទេស ដោយអះអាងថា គាត់មិនបានដឹងពីឯកសារបច្ចេកទេសបង្រៀនធ្វើទារុណកម្មដែលអនុវត្តនៅមន្ទីរសន្តិសុខផ្សេងឡើយ ។ របាយការណ៍របស់លោកបណ្ឌិ **Etcheson** ស្តីពីការធ្វើទារុណកម្ម គាត់លើកឡើងថា អ្នកទោសស្រីមួយចំនួនត្រូវបានដុតសុដន និងអ្នកទោសខ្លះទៀតត្រូវដាក់ឱ្យសត្វពិសខាំឬទិច ដែលនេះជាគំនិតច្នៃប្រឌិតថ្មីរបស់ជនជាប់ចោទ។

***ការយល់ដឹងអំពីជម្លោះប្រដាប់អាវុធ :*** **ឌុច** តែងទទួលស្គាល់ពីការកើតមានជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម ចាប់ពីប្រទេសទាំងពីរបានបញ្ឈប់ទំនាក់ទំនងការទូត កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ។ លោកស្រីចៅក្រម **Cartwright** បានដេញដោលឱ្យឃើញថា ជនជាប់ចោទមបានដឹងពីជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម មុនរយៈពេលនេះទៀត ។ ជនជាប់ចោទពន្យល់ថា ខ្លួនបានដឹងពីការតស៊ូតាំងពីយូរណាស់ហើយរវាងបក្សកុម្មុយនីស្តកម្ពុជា និងបក្សកុម្មុយនីស្តវៀតណាម ប៉ុន្តែខ្លួនមិនបានដឹងពីជម្លោះប្រដាប់អាវុធទេ ។ ជនជាប់ចោទនៅតែអះអាងថា គាត់បានដឹងច្បាស់ពីជម្លោះប្រដាប់អាវុធ គឺនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ ពេលដែល **ប៉ុល ពត** ប្រារព្ធមេទ្ធិញមួយ ស្តីពី *"មហាជ័យជំនះលើពួកវៀតណាម"* ។

***អ្នកទោសវៀតណាមនៅមន្ទីរ ស-២១ :*** នៅថ្ងៃពុធ បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ ត្រូវបានបង្ហាញដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពីចំនួនជនជាតិវៀតណាមនៅមន្ទីរ ស-២១ សរុប ៣៤៥នាក់ ដោយមិនរាប់បញ្ចូលកូនក្មេង ហើយជាចំនួនច្រើនលើសលុបបើធៀបនឹងជនបរទេសផ្សេងទៀត ។ អ្នកទោសវៀតណាមត្រូវបានចាត់ជាបីក្រុម គឺក្រុមទាហ៊ាន ក្រុមគិញ្ញ និងក្រុម

ជនស៊ីវិល ។ ជនជាប់ចោទបញ្ជាក់ថា មុនថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ អ្នកទោសជនជាតិវៀតណាមចូលមកមន្ទីរ ស-២១ មានចំនួនតិច តែក្រោយមកចំនួនបានកើនយ៉ាងខ្លាំង ជាពិសេស ទាហ៊ានឈ្លើយសឹកវៀតណាមដែលបញ្ជូនមកមន្ទីរ ស-២១ ។

***គោលនយោបាយកំទេចជនជាតិវៀតណាម :*** **ឌុច** បដិសេធមិនទទួលស្គាល់ថាមានគោលនយោបាយកំទេចជនជាតិវៀតណាម និងអ្នកទោសនៅមន្ទីរ ស-២១ ដោយសារការកំណត់ជាតិពន្ធទេ ។ ទាំងអ្នកទោសវៀតណាមដែលជាក្រុមជនស៊ីវិល និងគិញ ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ និងសម្លាប់ ដោយសារសកម្មភាពសម្ងាត់ ឬកំហុសរបស់ខ្លួន ។ **ឌុច** រំលឹកថា ចំពោះទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមជានិច្ចកាល *"ជម្រុញទៅរកសង្គ្រាម"* ព្រោះតែគោលនយោបាយពីរផ្សេងគ្នារវាង **ប៉ុល ពត** *"ឯករាជ្យម្ចាស់ការ"* និងបក្សកុម្មុយនីស្តវៀតណាម *"សហព័ន្ធឥណ្ឌូចិន"* ។

***ចម្លើយសារភាពអ្នកទោសវៀតណាមនៅមន្ទីរ ស-២១ :*** តាមរយៈ **ឌុច** បានឱ្យដឹងថា **ម៉ម ណៃ** ជាមនុស្សតែម្នាក់គត់ដែលតែងតាំងឱ្យសួរចម្លើយអ្នកទោសវៀតណាមនៅមន្ទីរ ស-២១ ដោយសារគាត់ចេះនិយាយភាសាវៀតណាម និងចង់ឱ្យគាត់ក្តាប់ការងារនេះឱ្យបានណែន ។ ចម្លើយសារភាពអ្នកទោសទាហ៊ានវៀតណាមត្រូវបានប្រើជាឧបករណ៍ឃោសនា ទាំងសំលេងសារភាព និងរូបថតអ្នកទោសត្រូវចាក់ផ្សាយតាមវិទ្យុ និងខ្សែភាពយន្ត នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៨ ។ **ឌុច** បញ្ជាក់ថា មានចម្លើយសារភាពមួយចំនួនត្រូវបានកែប្រែតាមបញ្ជាថ្នាក់លើ ហើយអ្នកទោសត្រូវបង្ខំឱ្យអាន និងទទួយកចម្លើយសារភាពនោះ ។ ការឃោសនាត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយជាសាធារណៈ ទាំងថ្នាក់ជាតិ និងអន្តរជាតិ ដែលថា ជនជាតិវៀតណាមចូលឈ្លានពានកម្ពុជា និងមានបំណងលេបទឹកដីកម្ពុជាបង្កើតជារដ្ឋសហព័ន្ធឥណ្ឌូចិន ។

### ខ- ការសង្កេតឃើញបញ្ហានាពេលសវនាការ

***សិទ្ធិរបស់ជនជាប់ចោទ :*** នាសប្តាហ៍នេះ មេធាវីការពារក្តីអន្តរជាតិលោក **François Roux** អវត្តមាន តែជំនួសដោយលោកស្រីមេធាវី **Carnizares** ។ សិទ្ធិជនជាប់ចោទហាក់ត្រូវបានរំលោភ ដោយសារមេធាវីការពារក្តីមិនសូវសកម្មក្នុងការការពារផលប្រយោជន៍ជនជាប់ចោទ ។ *<u>ឧទា :</u>* លោកស្រីមេធាវី **Carnizares** មិនបានជំទាស់នឹងការដេញដោលសហព្រះរាជអាជ្ញាទាក់ទងនឹងឯកសារដកស្រង់ពីសំណុំរឿងក្តីលេខ ០០២ អ្នកស្រីគ្រាន់តែបញ្ជាក់ថា ឯកសារទាំងនោះស្ថិតក្នុងសំណុំរឿងក្តីលេខ ០០២ ។

## ៣. ការចូលរួមរបស់ជនរងគ្រោះ និងសាក្សី និងការការពារជនរងគ្រោះ និងការគាំទ្រ

***វត្តមានដើមបណ្តឹងរដ្ឋប្បវេណី :*** ដើមបណ្តឹងរដ្ឋប្បវេណីបានកើនចំនួនពី ២ ទៅ ៣នាក់ នាសប្តាហ៍នេះ ដែលធ្វើឱ្យចំនួនសរុបមាន ៥ ទៅ ៦នាក់ ចូលរួមសវនាការ ហើយក្នុងចំណោមនោះមកពីក្រុម ២ និងក្រុម៤ ។

***ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យចូលរួមកិច្ចប្រជុំរៀបចំសវនាការ :*** នៅថ្ងៃច័ន្ទ អង្គជំនុំជម្រះបានប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវអនុញ្ញាតឱ្យចូលរួមកិច្ចប្រជុំរៀបចំសវនាការ ដែលនឹងរៀបចំជាអសាធារណៈនៅថ្ងៃប្រហស្បតិ៍ ក៏ប៉ុន្តែដើមបណ្តឹង

រដ្ឋប្បវេណីអាចមានជម្រើស ចូលរួម ឬមិនចូលរួម ។ សេចក្តីសម្រេចនេះឆ្លើយតបទៅសេចក្តីថ្លែងការណ៍របស់មេធាវីដើមបណ្តឹង លោកស្រី **Studzinski** នាសប្តាហ៍មុនដែលថា *"ដើមបណ្តឹងរដ្ឋប្បវេណីមិនគួរហាមឃាត់ក្នុងការចូលរួមកិច្ចប្រជុំរៀបចំសវនាការឡើយ ព្រោះផលប្រយោជន៍កូនក្តីខ្លួនអាចត្រូវប៉ះពាល់"* ។

***ការការពារសាក្សីកំឡុងពេលសិក្សាភស្តុតាង :*** អង្គជំនុំជម្រះបានបង្ហាញឱ្យឃើញពីការការពារសាក្សី កំឡុងពេលសហមេធាវីការពារក្តីអន្តរជាតិស្នើសុំចាក់បង្ហាញនូវខ្សែវីឌីអូរដកស្រង់ពីការសម្តែងឡើងវិញនៃដំណើរឆ្ពោះទៅមន្ទីរ ស-២១ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ នោះ លោកស្រីចៅក្រម **Cartwright** បានលើកឡើងថា តើខ្សែវីឌីអូនោះមានបង្ហាញពីសាក្សី ដែលមិនទាន់ផ្តល់សក្ខីកម្មទេ? ព្រោះសាក្សីទាំងនោះស្ថិតក្នុងការការពារ ហើយនៅប្រើឈ្មោះសម្ងាត់នៅឡើយ ។ សហមេធាវីការពារក្តីអន្តរជាតិទទួលស្គាល់ពីបញ្ហានោះ ថាពិតជាមានគ្រោះថ្នាក់ដល់សាក្សី នៅពេលអត្តសញ្ញាណពួកគេត្រូវបានបង្ហាញឱ្យដឹងមុន ។ អង្គជំនុំជម្រះបានផ្តល់ជម្រើសដល់លោកស្រីមេធាវីការពារក្តី ក្នុងការបង្ហាញភស្តុតាងជាអសាធារណៈ ឬផ្អាករងចាំពេលសមស្រប ។ លោកស្រីមេធាវីយល់ព្រមធ្វើនៅពេលក្រោយ ។

***ការសុំទោសសាក្សីបណ្តាលមកពីលើកការផ្តល់សក្ខីកម្ម :*** របាយការណ៍ឃ្លាំមើលតុលាការនាសបាហ៍មុន៧ បានកត់សម្គាល់ថាសាក្សីមានវត្តមាននៅតុលាការតែមិនបានផ្តល់សក្ខីកម្មខ្លួន ។ បញ្ហានេះកើតម្តងទៀត នៅថ្ងៃពុធ និងព្រហស្បតិ៍ នាសប្តាហ៍នេះ អង្គជំនុំជម្រះបានធ្វើការសុំទោសសាក្សី ព្រោះតែការប៉ាន់ស្មានពេលវេលាមិនត្រឹមត្រូវទៅតាមកាលបរិច្ឆេទ ។

***សំណួរច្រំដែល និងប្រាសចាកប្រធានបទ :*** កត់សម្គាល់ថា នាសប្តាហ៍នេះ មេធាវីដើមបណ្តឹងមានភាពអត់ធ្មត់ កំឡុងពេលសួរដេញដោលជនជាប់ចោទ ព្រោះប្រឹងប្រែងសួរដេញដោល និងសន្និដ្ឋានទៅតាមពេលវេលាកំណត់ ។ ប៉ុន្តែនៅតែមានសំណួរច្រំដែល ដោយមេធាវីដើមបណ្តឹងចង់បញ្ជាក់ពីសក្ខីកម្មរបស់ជនជាប់ចោទដែលមិនទាន់ច្បាស់ ។ តាមការអះអាងរបស់អង្គជំនុំជម្រះថា មានសំណួរក្រៅប្រធានបទកាលពីថ្ងៃអង្គារ ហើយក៏ទទួលស្គាល់ថា បញ្ហានេះពិតជាការពិបាកក្នុងការព្រិតព្រៀងសំណួរទៅតាមប្រធានបទ ។ ចំពោះសំណួរច្រំដែលភាគច្រើនចេញពីមេធាវីដើមបណ្តឹងជាតិ ដែលបញ្ហានេះបណ្តាលមកពីការបកប្រែ ឬការកំណត់ត្រារបស់ខ្លួន ។

នាថ្ងៃអង្គារ នៅពេលសហមេធាវីការពារក្តីអន្តរជាតិសួរដេញដោលជនជាប់ចោទ មេធាវីដើមបណ្តឹងក្រុម២ លោកស្រី **Silke Studzinski** បានជំទាស់នឹងការផ្តល់សក្ខីកម្មរបស់ជនជាប់ចោទ ផ្អែកលើមូលដ្ឋានថា របាយការណ៍ទាំងនេះស្ថិតក្រៅប្រធានបទ ។ លោកស្រី **Silke Studzinski** បានអះអាងថា សេចក្តីថ្លែងរបស់ជនជាប់ចោទបែរជាសម្តែងការសោកស្តាយវិប្បដិសារី និងការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់ខ្លួន ដែលប្រាសចាកពីប្រធានបទនៃការអនុវត្តន៍គោលនយោបាយនៅមន្ទីរ ស-២១ ប៉ុន្តែអង្គជំនុំជម្រះបានបដិសេធចោលការជំទាស់របស់លោកស្រី ដោយមិនបានបញ្ជាក់ពីមូលដ្ឋានច្បាស់លាស់ ។

## ៤. ការគ្រប់គ្រងផ្នែកដំណើរការជំនុំជម្រះ

***ការគ្រប់គ្រងផ្នែកតុលាការ :*** អង្គជំនុំជម្រះបានរំលឹកដល់ភាគីសារជាថ្មី ទាក់ទងនឹងការសួរដេញដោលជនជាប់ចោទនៅក្នុងដែនកំណត់ ចៀសវាងសំណួរច្រំដែល និងមិនច្បាស់លាស់ ។ នាសប្តាហ៍នេះ គួរកោតសរសើរអង្គជំនុំជម្រះ ដែលមិនត្រឹមតែធ្វើការក្រើនរំលឹកជាញឹកញាប់ដល់ភាគីប៉ុណ្ណោះទេ ប៉ុន្តែបានប្រឹងប្រែងយ៉ាងសកម្មបញ្ឈប់រាល់សំណួរចាកឆ្ងាយប្រធានបទ និងច្រំដែល ។ តែទោះជាយ៉ាងណា អង្គជំនុំជម្រះនៅតែបានណែនាំជាច្រើនលើកចំពោះករណីនេះ ។

កិច្ចប្រឹងប្រែងគួរឱ្យចាប់អារម្មណ៍មួយទៀតដែរ គឺការបង្កើនល្បឿនកិច្ចសវនាការ ។ កាលពីថ្ងៃច័ន្ទ ពេលដែលប្រធានអង្គជំនុំជម្រះបានបង្គាប់ឱ្យជនជាប់ចោទអនុវត្តសិទ្ធិមិនឆ្លើយតបនូវសំណួរច្រំដែល និងមិនចំប្រធានបទ ដែលវិធានការណ៍នេះបានបង្កើនល្បឿនកិច្ចសវនាការមួយកម្រិត ។

***កង្វល់នៃការបកប្រែ :*** បញ្ហានេះត្រូវបានបង្ហាញឱ្យឃើញដោយក្រុមអ្នកបកប្រែ លើការកែតម្រូវសេចក្តីថ្លែងការណ៍របស់ភាគី ។ ខណៈពេល **ឌុច** ប្រើពាក្យអសុរសឆ្លើយតបនឹងសក្ខីកម្មរបស់លោកបណ្ឌិត **Etcheson** (សូមមើលផ្នែក *ឥរិយាបថរបស់តុលាការ*) គឺមិនមានការបកប្រែជាភាសាបរទេសទេ ។

បញ្ហាមួយទៀត គឺថាចំណុចសំខាន់មួយចំនួនអាចត្រូវបាត់បង់ដោយការបកប្រែ ដូច្នេះភាគីទាមទារធ្វើការបញ្ជាក់ បើមិនដូច្នោះទេ នឹងបាត់បង់នូវព័ត៌ដែលខ្លួនចងបាន ។ លោកស្រីចៅក្រម **Cartwright** និងលោកចៅក្រម **Lavergne** បានធ្វើការសង្ខេបដោយប្រុងប្រយ័ត្ននូវព័ត៌មានដែលខ្លួនចងបាន និងយល់អំពីសក្ខីកម្មរបស់ជនជាប់ចោទ ។

***បញ្ហាបកប្រែឯកសារ :*** នៅថ្ងៃច័ន្ទ បានឱ្យដឹងថា មានបញ្ហានៃការបកប្រែឯកសារម្តងទៀត ពាក់ព័ន្ធនឹងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ។ តាមមាត្រា ២-ច នៃលក្ខន្តិកៈជាភាសាអង់គ្លេសលើកថា កិច្ចប្រជុំស្វ័យតិះទៀនគួរតែធ្វើឡើងជារៀងរាល់ថ្ងៃ ។ ចំណែកឯជនជាប់ចោទអះអាងថា អត្ថបទនេះជាភាសាខ្មែរមានន័យថា កិច្ចប្រជុំគួរតែធ្វើឱ្យបានញឹកញាប់ ។ បញ្ហានេះបានបង្កឱ្យមានការពិភាក្សាឡើងវិញដោយអង្គជំនុំជម្រះ អំពីសុពលភាពនៃឯកសារបកប្រែទាំងនោះ ។

***ចរិកលក្ខណៈនៅក្នុងបន្ទប់សវនាការ*** : កំឡុងពេលសួរដេញដោលជនជាប់ចោទ មេធាវីដើមបណ្តឹងក្រុម១លោក **Alain Werner** បានសួរជនជាប់ចោទពាក់ព័ន្ធនឹងសក្ខីកម្មរបស់លោកបណ្ឌិត **Craig Etcheson** ពេលនោះជនជាប់ចោទបានឆ្លើយតបហាក់ជាខឹងសម្បារ និងចាត់ទុកលោកបណ្ឌិត **Etcheson** ថាជា *"អ្នកនិពន្ធឆ្កួត"* ដែលសរសេរប្រឌិតអំពីគោលនយោបាយអនុវត្តន៍នៅមន្ទីរស-២១ ។ ភ្លាម១នោះ អង្គជំនុំជម្រះបានធ្វើការណែនាំដល់ជនជាប់ចោទ និងបង្គាប់ឱ្យជនជាប់ចោទប្រើសម្តីសមរម្យនៅក្នុងបន្ទប់សវនាការ ។

***ការចូលរួមពីមន្ត្រីតុលាការ និងសាធារណៈជន :*** ចាប់ផ្តើមតាំងពីថ្ងៃច័ន្ទ សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានជំនួសដោយលោក **William Smith** ។ សម្រាប់សប្តាហ៍នេះ មេធាវីការពារក្តីលោក **Franucois Roux** អវត្តមាន តែជំនួសដោយលោកស្រីមេធាវី

**Marie-Paule Carnizares** ចំណែកសហព្រះរាជអាជ្ញារងជាតិកាលពីថ្ងៃពុធ លោក **តាន់ សេណារ៉ុង** ត្រូវបានជំនួសដោយលោក **សេង ប៊ុនឃាង** ។

ការចូលរួមពីសាធារណៈជននៅសាលសវនាការ មានចំនួនច្រើនបង្គួរនៅថ្ងៃច័ន្ទ និងថ្ងៃអង្គារ ដោយប្រជាជនប្រមាណជា ១០០នាក់ មកពីខេត្តផ្សេងៗ រួមទាំងសហគមន៍ជនជាតិឥស្លាមមកពីខេត្តឆ្ងាយៗប្រមាណជា ៣០នាក់ មកពីស្រុកមេសាង ខេត្តព្រៃវែង និងចំនួន ៤០នាក់ មកពីស្រុកឆ្លូង ខេត្តក្រចេះ ព្រមទាំងមួយចំនួនទៀតមកពីសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ នៅថ្ងៃពុធ ប្រជាជនប្រមាណជា ៤០នាក់ មកពីឃុំចំនួន២ នៅក្នុងខណ្ឌចំនួន២ រាជធានីភ្នំពេញ ។ កត់សម្គាល់ថាជារៀងរាល់ថ្ងៃ ចំនួនអ្នកចូលរួមសវនាការត្រូវបានចុះថយ បន្ទាប់ពីសម្រាកអាហារថ្ងៃត្រង់ ។ ការចូលរួមរបស់ប្រជាជនទាំងនេះត្រូវបានឧបត្ថមថវិការដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បន្ថែមពីនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បាននាំសិស្ស-និស្សិតជនជាតិអាមេរិកប្រហែលជា ១០ នាក់ មកចូលរួមសវនាការនៅថ្ងៃពុធដែរ ។

***បញ្ហាបច្ចេកទេស :*** ប្រព័ន្ធរលកសម្លេងត្រូវបានរំខានដោយសំលេងរំញ័រ បណ្តាលមកពីវត្ថុម្យ៉ាង អាចជាទូរស័ព្ទដៃ ។ ដូច្នេះគួរតែកើនរំលឹកដល់អ្នកបកប្រែ គួរយកវត្ថុទាំងនោះដាក់ឱ្យឆ្ងាយពីឧបករណ៍បំពងសំលេង ។

***កម្មវិធីជំនុំជម្រះ :*** នាសប្តាហ៍នេះ សវនាការសាធារណៈប្រព្រឹត្តតែ ៣ថ្ងៃ ប៉ុណ្ណោះ ដោយហេតុថា នៅថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះរៀបចំសវនាការអសាធារណៈមួយ ស្តីពីកិច្ចប្រជុំរៀបចំសវនាការ ដែលរបៀបវារៈត្រូវបានប្រកាសឱ្យដឹងកាលពីថ្ងៃពុធ មានដូចខាងក្រោម :

១. ការប៉ាន់ប្រមាណពីរយៈពេល នៃកិច្ចដំណើរការនីតិវិធីសវនាការរហូតដល់ ខែធ្នូ ឆ្នាំ២០០៩
២. កិច្ចពិភាក្សាអំពីបញ្ហាដែលហួសពីលទ្ធភាពមេធាវីរបស់ភាគី ក៏ដូចជា បញ្ហារបស់បុគ្គលិក និងបញ្ហាផ្នែករដ្ឋបាល
៣. ចំនួនថ្ងៃដែលត្រូវធ្វើការ និង ចំនួនម៉ោង នៃកិច្ចដំណើរការនីតិវិធី
៤. ការឈប់សម្រាកសវនាការ
៥. សេចក្តីណែនាំអំពីការអនុវត្តវិធាន ៨៧-៣ និង ៨៧-៦ ដើម្បីជាពន្លឺដល់សំណើរបស់អង្គជំនុំជម្រះ ក្នុងការធ្វើវិសោធនកម្មលើវិធានទាំងនេះ
៦. ការកំណត់ពេលវេលាសំរាប់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងការណ៍ជាសាធារណៈ និង
៧. បញ្ហាផ្សេងៗ ដែលត្រូវលើកសម្រាប់ការពិចារណារបស់អង្គជំនុំជម្រះ ។

## ការគ្រប់គ្រងពេលវេលា

| ថ្ងៃ- កាលបរិច្ឆេទ | ចាប់ផ្តើម | សំរាក- ព្រឹក | អាហារថ្ងៃត្រង់ | សំរាក- រសៀល | បញ្ចប់ | សរុបចំនួនម៉ោង |
|---|---|---|---|---|---|---|
| ច័ន្ទ ០៨-០៦-០៩ | ០៩: ១៥ | ១០:៣០-<br>១១:០០ | ១២:០៥-<br>១៣:៣៥ | ១៤:៥០-<br>១៥:១៥ | ១៦:២៥ | ៤ម៉ ៣៥ នាទី |
| អង្គារ៍ ០៩-០៦-០៩ | ០៩:១០ | ១០:៤៥-<br>១១:០៥ | ១២:០៦-<br>១៣:៤៥ | ១៥:០០-<br>១៥:២៥ | ១៦:១៥ | ៤ម៉ ៤១នាទី |
| ពុធ ១០-០៦-០៩ | ០៩:១០ | ១០:៥០-<br>១១:១០ | ១២:០០-<br>១៣:៣៥ | ១៤:៥០-<br>១៥:២០ | ១៦:០០ | ៤ម៉ ២៥នាទី |
| ព្រហ. ២១-០៥-០៩ | - | - | - | - | - | - |

**ចំនួនម៉ោងជាមធ្យម : ៤ម៉ ៣៣ នាទី**

**ចំនួនម៉ោងសរុបនាសប្តាហ៍នេះ : ១៣ម៉ ៤១នាទី**

**ចំនួនសរុប ម៉ោង ថ្ងៃ និង សប្តាហ៍ នៅសវនាការ : ១១២ម៉ ២២នាទី នៃ ២៦ ថ្ងៃសវនាការ នៃសប្តាហ៍ទី ៧**

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** (“កម្មវិធី” ) : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៏រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៏ប្រចាំសប្តាហ៏ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្គិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៏ប្រចាំសប្តាហ៏នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមទី១**
- លោកស្រី **ជូ វិនាថ** : ប្រធានកម្មវិធីសង្កេតការណ៏តុលាករនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** : បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** : សិង្ហបុរី
- លោក **Florian Hansen** : អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** : ស្វីស
- កញ្ញា **Deepika Sharma** : សហរដ្ឋអាមេរិក

**ក្រុមទី២**
- កញ្ញា **សេក សុវណ្ណា** : មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សាវន** : បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** : ឥណ្ឌូនេស៊ី
- កញ្ញា **Romana Weber** : ស្វីស
- កញ្ញា **Binxin Zhang** : ចិន
- លោក **Jaspreet Dosanjh** : សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៏នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៏នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/_ ។